## មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្បទារបស់ជនជាប់ចោទក្នុងសំណុំរឿង០០២

នៅថ្ងៃទី ២៩-៣១ ខែសីហា ឆ្នាំ ២០១១ ខាងមុខនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) នឹងបើកសវនាការបឋមមួយទៀតដែលពាក់ពន្ធ័ទៅ នឹងសម្បទារបស់ជនជាប់ចោទ នួន ជា និងអៀង ធីរិទ្ធិ។ សម្បទារបស់ជនជាប់ចោទគឺ សំដៅទៅលើសមត្ថភាពរបស់ជនជាប់ចោទនៅក្នុងការចូលរួមនៅក្នុងដំណើរការសវនាការ ។ សមត្ថភាពរបស់ជនជាប់ចោទសំដៅទៅលើ សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទ ។ ជនជាប់ចោទអាចត្រូវបានកំណត់ថាមានសម្បទាគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការចូលរួមនៅក្នុងដំណើរការសវនាការបាន ល្គឹកណា តែជនជាប់ចោទមានលទ្ធភាព ឬសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តសិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវ នឹងយុត្តិធម៌របស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ។ ការចូលរួមរបស់ជនជាប់ចោទនៅក្នុងនីតិវិធីសវនាការគឺ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវត្តមានរបស់ជនជាប់ចោទគឺ បញ្ចៀសនូវសវនាការកំបាំងមុខ ដែលអាចធ្វើឲ្យតុលាការមិនមានភាពសុក្រិត និងអយុត្តិធម៌ ។ លើសពីនេះ ការចូលរួមរបស់ជនជាប់ចោទគឺ ដើម្បីធានានូវការកាត់ក្តីមួយដែលត្រឹមត្រូវ និងយុត្តិធម៌ ។

សវនាការនេះធ្វើឡើងដើម្បីបើកឲ្យមានការសួរដេញដោលទៅលើអ្នកជំនាញពីសំណាក់សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីការពារក្តីឲ្យជនជាប់ចោទទាក់ទងទៅនឹងការរបាយការណ៍របស់អ្នកជំនាញដែលបានវាយតម្លៃលើស្ថានភាពសម្បទារបស់ជនជាប់ចោទកាលពីពេលកន្លងមក ។ សហមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង ធីរិទ្ធិ និង នួន ជា បានអះអាងថាកូនក្តីរបស់ខ្លួនមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងសវនាការឡើយដោយសារ ជនជាប់ចោទទាំងពីរសុទ្ធតែមានអាយុច្រើន ខ្លះមានជម្ងឺភ្លេចភ្លាំង និងបាត់ការចងចាំ ខ្លះមានបញ្ហាសម្ពាធឈាមឡើងខ្ពស់ ។ ដូច្នេះសួរថា ប្រសិនជនជាប់ចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ

តើចៅក្រមនឹងសម្រេចយ៉ាងដូចម្តេច? ចម្លើយ គឺវាអាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងដំណើរការសវនាការទេនោះ តុលាការមិនអាចបន្តការកាត់ក្តីលើជនជាប់ចោទបានទេ។ ហេតុនេះ តុលាការត្រូវផ្អាកនីតិវិធី ហើយព្យាបាលជនជាប់ចោទរហូតដល់បានជាសះស្បើយទើបអាចបន្តរ នីតិវិធីបាន។

ថ្វីត្បិតតែច្បាប់ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបានចែងឲ្យច្បាស់អំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងដំណើការនីតិវីធីក៏ដោយ ប៉ុន្តែច្បាប់ និងវិធានផ្ទៃក្នុងបានចែងអំពីសិទ្ធក្នុងការចូលរួមរបស់ជនជាប់ចោទនៅក្នុងដំណាក់កាលជំនុំជម្រះ។ ការចូលរួមរបស់ជនជាប់ចោទត្រូវបានបញ្ញតិក្នុងវិធាន ៨១នៃវិធានផ្ទៃក្នុង ដែលទាមទាឲ្យមានវត្តមានជនជាប់ចោទនៅរាល់ការជំនុំជម្រះទាំងអស់។ មិនតែប៉ុនោះ មាត្រា៣៣ និងមាត្រា៣៥នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏តម្រូវឲ្យមានការចូលរួមរបស់ជនជាប់ចោទដែរ ដោយផ្អែកទៅលើកាគោរពសិទ្ធជនជាប់ចោទក្នុងការចូលរួមដំណើការនីតិវីធីតុលាការដូចមានចែងក្នុងមាត្រា១៤ និង១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធប្រជាពលរដ្ឋ និងសិទ្ធនយោបាយ ដើម្បីធានាឲ្យបាននូវការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌។ ម្យ៉ាងទៀត មាត្រា៣៣នៃច្បាប់របស់អ.វ.ត.កក៏អនុញ្ញាតឲ្យមានការប្រើប្រាស់ស្តង់ដារអន្តរជាតិមកដោះស្រាយរាល់បញ្ហាដែលច្បាប់ និងវិធានអ.វ.ត.ក មិនបានចែងច្បាស់លាស់។

ដើម្បីធានាបាននូវស្តង់ដារអន្តរជាតិតុលាកាត្រូវមើលទៅលើការអនុវត្តន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិរបស់បណ្តាប្រទេសនានាលើពិភពលោក។ គេឃើញមានរឿងក្តីមួយ កើតមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី ដែលមានជនជាប់ចោទឈ្មោះ ស្រ្តូហ្គា មានលក្ខណៈស្រដៀងនឹងរឿងក្តីរបស់ នួន ជា ដែរ ពាក់ពន្ធ័នឹងសម្បទាក្នុងការចូលរួមសវនាការ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវីបានកំណត់ថា ដើម្បីឲ្យជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងសវនាការ ជនជាប់ចោទត្រូវមានសមត្ថភាពគ្របគ្រាន់ក្នុងការអនុវត្តសិទ្ធ របស់ខ្លួនប្រកបដោយប្រសិទ្ធិភាព។ ដើម្បីអនុវត្តសិទ្ធិឲ្យមានប្រសិទ្ធិភាពនោះយ៉ាងហោចណាស់ជនជាប់ចោទត្រូវមាន

សមត្ថភាពអប្បបរមា ដូចជា៖ ១) ជជែកតតាំងដើម្បីការពារខ្លួននៅក្នុងសវនាការ ២) អាចយល់ដឹងពីបទល្មើសដែលគេចោទមកលើខ្លួន ៣) អាចយល់ដឹងពីកិច្ចដំណើរការនីតិវិធី ៤) អាចយល់ដឹងពីផលវិបាកនិងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី(ការដាក់ទោស) ៥) អាចយល់ដឹងពីភាពលម្អិតនៃភស្តុតាង ៦) អាចផ្តល់ព័ត៌មានទៅមេធាវីរបស់ខ្លួន ៧) ជនជាប់អាចផ្តល់សក្ខីកម្មបាន ។

ក៏ប៉ុន្តែអ្វីដែលសំខាន់នៅក្នុងសវនាការថ្ងៃទី២៩ដល់ទី៣១សីហា ២០១១ ខាងមុខនេះ មិនមែនជាសវនាការដែលធ្វើការសំរេចថាជនជាប់ចោទមាន រឺមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះទេ គឺវាគ្រាន់តែជាសវនាការមួយដើម្បីធ្វើការសំរេចលើការចាត់តាំងអ្នកជំនាញឲ្យធ្វើការវាយតម្លៃលើសម្បទាតាមរបស់ជនជាប់ចោទតែប៉ុណ្ណោះ ហើយបើសិនជាមានការចាត់តាំងឲ្យ តើរូបមន្តបែបណាដែលអនុញ្ញាតឲ្យតុលាការកំណត់ថាជនជាប់ចោទ មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។